# អធិដ្ឋាន



បើនាងកជ្រី អាចចាប់ជាតិថ្មី ជាកែវមនោរម្យ៍
ឱ្យចៅឫទ្ធិសែន ជាសុធនណា តាមលោមស្នេហា
ដល់ឋានកៃលាស។

រូបខ្ញុំនេះនៃ បើចាប់ជាតិថ្មី បារមីស្តើងគ្រាស់
សូមអន្ទោលតាម ជួបរៀមជាម្ចាស់ ដួងចិត្តពិតច្បាស់
ឥតក្រលះហោង។

គ្រប់ភពគ្រប់ជាតិ សូមជួបបងទៀត កុំឃ្លាតបំណង
រួមសុខរួមទុក្ខ អស់កប្បតែម្តង តាមដោយគន្លង
វង់វដ្តសង្សារ។



សូមអស់ទេវៈ ទាំងម៉ឺនលោកចក្រ ជួយចាំសច្ចា
ពាក្យអធិដ្ឋាន នៃខ្ញុំផងណា សូមឱ្យប្រាថ្នា
បានសមហឫទ័យ។

សូមកុសលបុណ្យ ខ្ញុំសាងពីមុន តិចក្តីច្រើនក្តី
មូលមកជាទុន ជាគុណប្រពៃ ជួយឱ្យប្រុសថ្លៃ
ចាំជាប់ចិន្តា។

ជាប្រុសនឹមនួន ហើយនឹងរូបប្អូន ជាគូស្នេហា
បុព្វសន្និវាស ឈ្វាសធ្លាក់ចងចារ ប្អូននិងរៀមរ៉ា
ជាគូព្រេងពិត។

បើបានដូចប៉ង ផលស្នេហ៍មកផង ផ្សងបានដូចចិត្ត
សូមបូជាកាយ ថ្វាយទាំងជីវិត ដល់ក្តីបពិត្រ
សុចរិតរៀងអើយ។៚

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី